# ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ដាក់បទបញ្ជាទៅមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី-ខេត្ត ត្រូវលុបបំបាត់នូវរាល់សិប្បកម្មផលិតស្ករត្នោតក្លែងក្លាយ ក្នុងព្រះរាជាណាចក្រកម្ពុជា



បន្ទាប់ពីបានបញ្ជូនក្រុមការងារបច្ចេកទេសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយមានការសហការជាមួយអាជ្ញាធរខេត្តតាកែវ ក្នុងការចុះទៅពិនិត្យ ស្រាវជ្រាវ និងធ្វើការវិភាគយ៉ាងម្មត់ចត់ផលិតផលស្ករត្នោតក្លែងក្លាយ និងទីតាំងសិប្បកម្មផលិតស្ករត្នោតក្លែងក្លាយ នៅស្រុកបាទី ខេត្តតាកែវ រួចរាល់មក នាពេលកន្លងទៅថ្មីៗនេះ ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានបញ្ជាទៅមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី ខេត្ត ទាំង ២៥ ឱ្យលុបបំបាត់ជាបន្ទាន់ នូវរាល់សិប្បកម្មផលិតស្ករត្នោតក្លែងក្លាយ នៅទូទាំងប្រទេស។

តាមខ្លឹមសារលិខិតរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលចុះហត្ថលេខានាថ្ងៃអង្គារ ០៩រោច ខែមគសិរ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ ដោយ ឯកឧត្តមទេសរដ្ឋមន្ត្រី ផ្ញើជូនប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី ខេត្ត ទាំង ២៥ ទូទាំងប្រទេស បានបញ្ជាក់ថា កន្លងមកមានការផលិតស្ករត្នោតក្លែងក្លាយ ដែលបានផលិតចេញពីវត្ថុធាតុដើមស្ករស ឬស្ករប្រភេទផ្សេងទៀត ហើយបានកែច្នៃទៅជាផលិតផលស្ករដែលមានរសជាតិ ក្លិន ពណ៌ និងទ្រង់ទ្រាយដូចគ្នាទៅនឹងស្ករត្នោត និងបានយកទៅចរាចរលើទីផ្សារ

បន្លំធ្វើជាស្ករត្នោតខ្មែរ។ សកម្មភាពនេះ គឺជាវិច្ឆេទកម្មសេដ្ឋកិច្ចដើម្បីបំផ្លាញកិត្តិនាមស្ករត្នោតខ្មែរ ដែលជាអត្តសញ្ញាណផលិតផលជាតិកំពុងត្រូវបានទទួលស្គាល់ជាសាធារណៈ ទាំងក្នុងនិងក្រៅប្រទេស។ ដូច្នេះ ក្រសួងសូមធ្វើការណែនាំដល់គ្រប់មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី ខេត្ត ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើការលុបបំបាត់រាល់សិប្បកម្មផលិតស្ករត្នោត ក្លែងក្លាយ ចាប់ពីពេលនេះតទៅ។

គួររំឭកផងដែរថា នាពេលកន្លងទៅថ្មីៗនេះ មានបាតុភាពមួយបានកើតឡើងនៅស្រុកបាទី ខេត្តតាកែវ គឺការផលិតនូវផលិតផលស្ករត្នោត ដែលប្រើប្រាស់ជាតុផ្សំពីស្ករស ១០០% ដោយយកទៅកម្លោច លាយទឹក រួចយកទៅកូរវិក ធ្វើឱ្យមានរូបភាពដូចស្ករត្នោតពិត។ បន្ទាប់ពីទទួលបានព័ត៌នេះភ្លាម ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក៏ដូចជាអាជ្ញាធរខេត្តតាកែវ បានចេញបញ្ជា ផ្អាកជាបណ្តោះអាសន្ន នូវសកម្មភាពផលិតស្ករត្នោតក្លែងក្លាយទាំងនោះ និងបានបញ្ជូនក្រុមមន្ត្រីជំនាញបច្ចេកទេស នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម សហការជាមួយ អាជ្ញាធរខេត្តតាកែវ ចុះទៅពិនិត្យ ស្រាវជ្រាវ និងវិភាគ ពីបញ្ហានេះ ហើយនៅពេលការពិនិត្យ និងវិភាគ បានប្រព្រឹត្តទៅចប់សព្វគ្រប់។ ឯកឧត្តមទេសរដ្ឋមន្ត្រី ក៏ចេញបញ្ជាឱ្យលុបបំបាត់ជាបន្ទាន់ នូវរាល់សិប្បកម្មផលិតស្ករត្នោតក្លែងក្លាយនៅទូទាំងប្រទេស។

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៣០០៥ MIH / ២០១៧

រាជធានីភ្នំពេញ ថ្ងៃ០៩រោច ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ត្រូវនឹងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧

**ជម្រាបជូន**

**លោកប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី-ខេត្ត**

**កម្មវត្ថុ ៖** ករណីលុបបំបាត់សិប្បកម្មផលិតស្ករត្នោតក្លែងក្លាយ នៅតាមបណ្តារាជធានី/ខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាប លោកប្រធានមន្ទីរ ជ្រាបថា ៖ កន្លងមកមានការផលិតស្ករត្នោតក្លែងក្លាយដែលបានផលិតចេញពីវត្ថុធាតុដើមស្ករស ឬស្ករផ្សេងទៀត ហើយបានកែច្នៃទៅជាផលិតផលស្ករដែលមានរសជាតិ ក្លិន ពណ៌ និងទ្រង់ទ្រាយដូចគ្នាទៅនឹងស្ករត្នោត និងបានយកទៅចរាចរលើទីផ្សារបន្លំធ្វើជាស្ករត្នោតខ្មែរ។ សកម្មភាពនេះ គឺជាវិច្ឆេទកម្មសេដ្ឋកិច្ចដើម្បីបំផ្លាញកិត្តិនាមស្ករត្នោតខ្មែរ ដែលជាអត្តសញ្ញាណផលិតផលជាតិកំពុងត្រូវបានទទួលស្គាល់ជាសាធារណៈទាំងក្នុង និងក្រៅប្រទេស។ ដូច្នេះ ក្រសួងសូមធ្វើការណែនាំដល់គ្រប់មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានីខេត្តទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើការលុបបំបាត់រាល់សិប្បកម្មផលិតស្ករត្នោតក្លែងក្លាយ ចាប់ពីពេលនេះតទៅ។

អាស្រ័យហេតុនេះ សូម លោកប្រធានមន្ទីរ អនុវត្តតាមខ្លឹមសារការណែនាំខាងលើឲ្យមានប្រសិទ្ធភាពខ្ពស់។

សូម លោកប្រធានមន្ទីរ ទទួលនូវការរាប់អាន អំពីខ្ញុំ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**ចម្លងជូន ៖**
- គ្រប់សាលារាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ